**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ជូនក្រសួងការពារជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងយុត្តិធម៌, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៣ | ឥណទានមុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | ការផ្ទេរចេញ | | | | 80.092.300 | |
| | ៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | | | | 80.092.300 | |
| 69 | ចំណាយមិនបានគ្រោងទុក | 1.713.847.000 | 1.096.522.400 | - | 80.092.300 | 1.016.430.100 |
| | ការផ្ទេរចូល | | | 80.092.300 | | |
| | ០៦-ក្រសួងការពារជាតិ | | | 3.354.000 | | |
| 60 | ការទិញ | 332.741.000 | 339.814.400 | 3.354.000 | - | 343.168.400 |
| | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | 6.166.300 | | |
| 60 | ការទិញ | 80.903.400 | 81.428.900 | 4.249.000 | - | 85.677.900 |
| 61 | សេវាកម្ម | 64.798.300 | 64.965.500 | 1.917.300 | - | 66.882.800 |
| | ២៦-ក្រសួងយុត្តិធម៌ | | | 1.602.000 | | |
| 60 | ការទិញ | 13.162.000 | 13.162.000 | 65.000 | - | 13.227.000 |
| 62 | អត្ថប្រយោជន៍សង្គម | 4.646.000 | 4.646.000 | 1.537.00 | - | 6.183.000 |
| | ៣២-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | 68.970.000 | | |
| 62 | អត្ថប្រយោជន៍សង្គម | 31.084.000 | 31.084.000 | 68.970.000 | - | 100.054.000 |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)- ផ្តល់ជូនក្រសួងការពារជាតិចំនួន ៣ ៣៥៤ លានរៀល សម្រាប់របបឧបត្ថម្ភស្បៀង (អង្ករ), ឯកសណ្ឋាន, សំលៀកបំពាក់, និងការតុបតែងផ្សេងៗរបស់ពលទាហានជ្រើសរើសថ្មីចំនួន ២ ៦០៦ នាក់។

២)- ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិកចំនួន ៦ ១៦៦,៣ លានរៀល សម្រាប់ចំណាយលើការបោះពុម្ពត្រាតយ និងតែមប្រើអាករ ការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ការទូទាត់ថ្លៃជួលអគារ ការតភ្ជាប់បណ្តាញទឹក ភ្លើង និងប្រព័ន្ធ FMIS ក្នុងអគាររដ្ឋបាល និងបេសកកម្មក្នុងនិងក្រៅប្រទេស សម្រាប់បន្តនិរន្តរភាពដំណើរការរដ្ឋបាលក្នុងឆ្នាំ ២០២៣។

៣)- ផ្តល់ជូនបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជានៃក្រសួងយុត្តិធម៌ សម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិក ចំនួន **១ ៦០២ លានរៀល** សម្រាប់ចំណាយលើការប្រើប្រាស់អគ្គិសនី ទឹក និងអាហារូបករណ៍សម្រាប់ការស្រាវជ្រាវក្នុងប្រទេស។

៤)- ផ្តល់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន **៦៨ ៩៧០ លានរៀល** សម្រាប់ទូទាត់ថវិកាបុរេប្រទានលើចំណាយរៀបចំកម្មវិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី និងចំណាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។**

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២ កើត ខែ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ